ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ✻ ៥៥

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៦៧/សម៌ណ ធទឧ

# សេចក្តីជូនដំណឹងលើកទី ២
# ស្តីពី ស្ថានភាពទឹកជំនន់ទន្លេមេគង្គ

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកទន្លេមេគង្គរួចមក ឃើញថា ជ្រលងសម្ពាធទាប ដែលបានកើតឡើងបន្ទាប់ពីព្យុះទី 9 ឈ្មោះ **រ៉ាម៉ាសាន់** បាន និងកំពុងបន្តមានឥទ្ធិពលខ្លាំងលើអាងទន្លេមេគង្គ ដោយបង្កឱ្យមានភ្លៀងធ្លាក់ច្រើននៅក្នុងផ្ទៃអាង ពិសេសនៅអាងទន្លេណាមមូន និងណាមឈី ក្នុងប្រទេសថៃ ។

ស្ថានភាពខាងលើនេះ នឹងធ្វើឱ្យទឹកទន្លេមេគង្គបន្តហក់ឡើងជាបន្តបន្ទាប់ ។ យោងតាមការព្យាករណ៍កម្ពស់ទឹកជំនន់ទន្លេមេគង្គ បានបង្ហាញថា ក្នុងរយៈពេលពី 02 ទៅ 04 ថ្ងៃខាងមុខ ទឹកទន្លេមេគង្គលើ នឹងហក់ឡើងដល់ :

- ខេត្តស្ទឹងត្រែង : **ទឹកនឹងហក់ឡើងខ្ពស់ជាងកម្រិតប្រកាសឱ្យមានការប្រុងប្រយ័ត្ន** ចាប់ពីថ្ងៃទី 01 ដល់ថ្ងៃទី 03 ខែសីហា ឆ្នាំ 2014 ។
- ខេត្តក្រចេះ និងខេត្តកំពង់ចាម : ទឹកនឹងហក់ឡើងដល់កម្រិតប្រកាសឱ្យមានការប្រុងប្រយ័ត្ន ចាប់ពីថ្ងៃទី 03 ដល់ថ្ងៃទី 04 ខែសីហា ឆ្នាំ 2014 ។

ដោយឡែក ចំពោះទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់ ទឹកក៏នឹងបន្តហក់ឡើងជាបន្តបន្ទាប់ ។ បើទោះបីជាបណ្តាទន្លេទាំងនេះ កម្ពស់ទឹកមិនទាន់ឡើងខ្ពស់ដល់កម្រិតប្រកាសឱ្យមានការប្រុងប្រយ័ត្នក្តី ប៉ុន្តែទឹកនឹងហូរចូលគ្រប់បណ្តាព្រែកទាំងអស់ ព្រមទាំងបណ្តាលឱ្យលិចតំបន់ទំនាបផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ សូមមានវិធានការណ៍ និងបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់បំផុត ចំពោះស្ថានភាពទឹកជំនន់ខាងលើនេះ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៤*

**រដ្ឋមន្ត្រី**

**លឹម_គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh